# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២២-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២៥ ស្តីពីការតែងតាំង ឯកឧត្តម **ឡុច សារ៉េត** ជា ឧកញ៉ា | ២៧៤៤ |
| ២៣-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២៦ ស្តីពីការតែងតាំង ឯកឧត្តម **ប្រ៉ាច សុផាន់** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ២៧៤៥ |
| ២៣-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២៧ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំ នៃអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋចំនួន៧ រូបបន្ថែមលើមុខងារ បច្ចុប្បន្ន | ២៧៤៦ |
| ២៦-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២៨ ស្តីពីការតែងតាំង ឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ២៧៤៧ |
| ២៦-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២៩ ស្តីពីការតែងតាំង ឯកឧត្តមបណ្ឌិត **គង់ ថៃ** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ចសង្គមកិច្ច និង វប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ២៧៤៨ |
| ២៦-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣០ស្តីពីការតែងតាំងលោកជំទាវ **ហេឡិន ចាវិស** (HELEN JARVIS)ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីមានឋានៈស្មើ **រដ្ឋលេខាធិការ** | ២៧៤៩ |
| ២៦-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣១ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **សេនា ជ័យសិទ្ធ** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៣ រូបដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ | ២៧៥០ |
| ២៦-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣២ ស្តីពីការតែងតាំង ឯកឧត្តម **ញាណ ទិមុល** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ២៧៥២ |
| ២៧-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣៣ ស្តីពីការតែងតាំង ឯកឧត្តម **ឃ្លោក ប៊ុតឌី** ជាអនុប្រធានគណៈកម្មការជាតិរៀបចំការបោះឆ្នោត ជំនួសឯកឧត្តម **ទ៊ែ ឆាយលាង** ដែលបានសុំលាលែង | ២៧៥៣ |

| | | |
|---|---|---|
| ២៧-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣៤ ស្តីពីការតែងតាំងឯកឧត្តម **ង៉ាន ឈាង** ជាទីប្រឹក្សាអមក្រសួងផែនការមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន | ២៧៥៤ |
| ២៧-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣៥ ស្តីពីការតែងតាំងឯកឧត្តម **មិន ចណ្ឌីណារុធ** ជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលមានឋានៈស្មើ **អគ្គនាយក** | ២៧៥៥ |
| ២៧-១១-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៣៦ ស្តីពីការប្រោសព្រះរាជទានចំពោះ ឧកញ៉ា **ម៉ុង ឫទ្ធី** នូវគ្រឿង ឥស្សរិយយស **សុវត្ថារា ថ្នាក់ មហាសេនា** | ២៧៥៦ |
| ០៣-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៤៥ ត្រូវបានដាក់ឯកឧត្តម **ពេជ្រ ប៊ុនធិន** ឧត្តមមន្ត្រីថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល រហូតដល់មានការសំរេចជាថ្មី | ២៧៥៧ |
| ០៤-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៤៨ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃព្រះរាជាណាចក្រកម្ពុជា | ២៧៥៨ |
| ០៤-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៤៩ ស្តីពីការតែងតាំង លោក **សាន់ សេងហាក់** ជា ឧកញ៉ា | ២៧៦២ |
| ០៤-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៥០ ស្តីពីការតែងតាំង ឯកឧត្តម **គឹង វណ្ណៈ** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកកសិកម្ម និងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស | ២៧៦៣ |
| ០៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០៥៣ ស្តីពីការតែងតាំង ឯកឧត្តម **យុ គិមយាន** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** | ២៧៦៤ |
| ០៧-១២-២០០៤ | -ព្រះរាជក្រឹត្យ នស/រកត/១២០៤/០៥៤ ស្តីពីការតែងតាំង ឯកឧត្តម **ថោង ខុន** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន | ២៧៦៥ |


## II~ក្រុមប្រឹក្សាធម្មនុញ្ញ


| | | |
|---|---|---|
| ០៣-១២-២០០៤ | -សេចក្តីសំរេចលេខ ០៦៦/០០៨/២០០៤ កបធ.ច ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ | ២៧៦៦ |
| ០៣-១២-២០០៤ | -សេចក្តីសំរេចលេខ ០៦៧/០០៩/២០០៤ កបធ.ច ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ | ២៧៦៨ |
| ០៧-១២-២០០៤ | -សេចក្តីសំរេចលេខ ០៦៨/០១០/២០០៤ កបធ.ច ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ | ២៧៧០ |

# គ

## III.រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៤-១១-២០០៤ -អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការកែសម្រួល ផ្លាកសញ្ញាសម្រាប់ពាក់លើមួក ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍ និងឯកសណ្ឋានការងារលេខ ៤ នៃអនុក្រឹត្យលេខ ៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ១៩៩៧ និងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៣ ២៧៧២

០៨-១២-២០០៤ -អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកាជូនទីស្តីការគណៈរដ្ឋមន្ត្រី ២៧៧៦

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៧៧៩

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៨០

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៨១

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧៨២

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៧៨៤

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៨៥

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៨ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ២៧៨៦

០៧-១២-២០០៤ -អនុក្រឹត្យលេខ ៦១៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៧៨៧


## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


០១-១២-២០០៤ -សារាចរណែនាំលេខ ៣៦៥ សរណែន.កសក ស្តីពីវិធានការ អនុវត្តការងារបង្កបង្កើនផលស្រូវប្រាំង ឆ្នាំ ២០០៤-២០០៥ ២៧៨៨


### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ


១៨-១១-២០០៤ -ប្រកាសលេខ ៤២៥ ក.ក.ប.វ ស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល ២៧៩០

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

## តែងតាំង

ឯកឧត្តម ឡុច សារ៉េត

ជា

## ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ការ.០៤១១.០២៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខ ៦៧៦ ចប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង ត្រាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើ ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម ប្រាក់ សុផាន់ ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយ ណាដែលមានខ្លឹមសារផ្ទុយនឹង ព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១ល.០៤១១.០២៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខ ២៩៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ១២ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាវ ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេច នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងសមាសភាពថ្នាក់ដឹកនាំ នៃអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ បន្ថែមលើ មុខងារបច្ចុប្បន្ន ដូចមានរាយនាមដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម | **សុខ អាន** | ជាអគ្គស្នងការ |
| ២-លោកជំទាវ | **អ៊ុំ កន្ថាជាវី** | ជាអគ្គស្នងការរង |
| ៣-ឯកឧត្តម | **ត្រាំ សុខា** | ជាអគ្គស្នងការរង |
| ៤-ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | ជាអគ្គស្នងការរង |
| ៥-ឯកឧត្តម | **ទេវ ហុងណី** | ជាអគ្គស្នងការរង អចិន្ត្រៃយ៍ |
| ៦-ឯកឧត្តម | **ឆឹយ ម៉ឿន** | ជាអគ្គស្នងការរង |
| ៧-ឯកឧត្តម | **គឹមសយ សារ៉ាវ៉ែឡុន** | ជាអគ្គស្នងការរង |

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

៣រ.ល.០៤១១.០២៧ **នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៤

លេខ: ...ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**...ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង :

១- ឯកឧត្តម **ស៊ា ស៊ាមណី** ទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទមានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម **ហេង នាងឈីន** ទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទមានឋានៈស្មើ អនុរដ្ឋលេខាធិការ
៣- ឯកឧត្តម **ឡេង តឹកសេង** ទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទមានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣/ល-០៤១១-០២៨

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ ២៩៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តមបណ្ឌិត **គង់ ថៃ** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ការ.០៤១១-០៤៩*

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ: ២៩៧ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០៣០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងលោកជំទាវ **ហេឡិន ចាវិស** (HELEN JARVIS) ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពរល.០៤១១.០៣០*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ: [illegible] ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

នស/រកត/១១០៤/០៣១

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានតភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បំពាក់គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ជូននាយទាហានជាន់ខ្ពស់ នៃ កងយោធពលខេមរភូមិន្ទ ចំនួន ១៣រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ឯក **សំ ចន្ទណ្ណថន** | អត្តលេខ ០០០២០៥ | អគ្គលេខាធិការ ក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ឯក **មាស សំអុល** | អត្តលេខ ០០០២១១ | នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ |
| ៣-ឧត្តមសេនីយ៍ឯក **ឈី ដេត** | អត្តលេខ ០០០០២៩ | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ |
| ៤-ឧត្តមសេនីយ៍ឯក **យឹម សារី** | អត្តលេខ ០០០០៧៧ | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ និង ជានាយក នាយកដ្ឋានប្រេងឥន្ធនៈ |
| ៥-ឧត្តមសេនីយ៍ឯក **ខេង មុនឧក្ឫាយ** | អត្តលេខ ០០០០៨២ | អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ |
| ៦-ឧត្តមសេនីយ៍ឯក **ឈឹម សុខគ្គិ** | អត្តលេខ ០០០០៦៩ | ជាទីប្រឹក្សា និង ជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **នៀ បាញ់** |
| ៧-ឧត្តមសេនីយ៍ឯក **ប្រាក់ ម៉ារឌី** | អត្តលេខ ០០០០៨១ | អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា |

| | | | |
|---|---|---|---|
| ៨-ឧត្តមសេនីយ៍ឯក **ហេង ហុង** | អត្តលេខ ០០០១២៧ | នាយរង សេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន |
| ៩-ឧត្តមសេនីយ៍ឯក **ឆៀ សុន្ទ** | អត្តលេខ ០០០២២៩ | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ១០-ឧត្តមសេនីយ៍ឯក **ជួ ផាន់** | អត្តលេខ ០០០២២៨ | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស |
| ១១-ឧត្តមសេនីយ៍ឯក **ផន ឈារ៉ា** | អត្តលេខ ០០០០៧៨ | អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស និង ជានាយក នាយកដ្ឋានបញ្ជូនសារ |
| ១២-ឧត្តមសេនីយ៍ឯក **ជុំ ឃាត់** | អត្តលេខ ០០០២៧២ | មេបញ្ជាការរង កងទ័ពជើងគោក |
| ១៣-ឧត្តមសេនីយ៍ឯក **អ៊ុន ចាន់ថា** | អត្តលេខ ០០០៤៧០ | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ |

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣ាល.០៤១១.០៣១*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ:៧៩៩ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

នស/រកត/១១០៤/០៣២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **ញាណ ទិបុណ** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការ.០៤១១.០៣២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខ: ៣០០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សូរ ធី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរស្សិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/១១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣
- បានទ្រង់យល់លិខិតលេខ ២៣៨ រស. ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីលទ្ធផលនៃការបោះឆ្នោតសំដែងការយល់ព្រមលើបេក្ខភាពឯកឧត្តម ឃ្លោក ប៊ុតឌី នាថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ឃ្លោក ប៊ុតឌី** ជាអនុប្រធានគណៈកម្មការជាតិរៀបចំការបោះឆ្នោត ជំនួសឯកឧត្តម **ខៃ ឆាយឈាង** ដែលបានសុំលាលែង ។

**មាត្រា ២** : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្ត អោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

៣រល.០៤១១.០៣៣

លេខ: ៣០១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាវ៉ី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម **ឆាន់ លាង** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៤*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣.រ.ល.០៤១១.០៣៤*

លេខ ៣០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឈាវ ឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **មិន ចណ្ឌីណារុធ** ជាអគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តរល.០៤១១.០៣៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខៈ ៣០៧ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា ម៉ុង ឫទ្ធី

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៤១១.០៣៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខ: ...០៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៩ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

នស/រកត/១២០៤/០៩៥

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៥១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការផ្ទេរសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌថ្មី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដាក់ ឯកឧត្តម **ពេជ្រ ប៊ុនធិន** ឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល រហូតដល់មានការសំរេចជាថ្មី ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ ២០០៤

តរាល.០៤១២.០៤៥

លេខៈ ១១០៥ច.ល
ចំលងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៤៨

## ស្តីពី

## ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

## នៃព្រះរាជាណាចក្រកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៤

**ត្រាស់បង្គាប់**

**មាត្រា ១.-**

បង្កើតឱ្យមានមូលនិធិមួយដើម្បីជួយអភិវឌ្ឍន៍អគ្គិសនីជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះថា "មូលនិធិអគ្គិសនីការូបនីយកម្មជនបទ" សរសេរកាត់ថា "**ម.អ.ជ.**" ។

**មាត្រា ២.-**

**ម.អ.ជ.** ត្រូវបង្កើតឡើងដាច់ដោយឡែក ជាស្ថាប័នសាធារណៈស្វយ័តមានលក្ខណៈសង្គមកិច្ច ហើយមានស្វ័យភាពក្នុងការគ្រប់គ្រងរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់នៃព្រះរាជាណា ចក្រកម្ពុជា ។

**មាត្រា ៣.-**

គោលបំណងនៃការបង្កើត **ម.អ.ជ.** គឺ ៖

១- ជំរុញឱ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឱ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃដែលអាចជាវបានសំរាប់សេដ្ឋកិច្ច សង្គម និងលំនៅស្ថានរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

២- ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឱ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅជនបទ ប្រកបដោយចិរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថាមពលថ្មី និងថាមពលកកើតឡើងវិញដែលមានលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្មសមស្រប ។

**មាត្រា ៤.-**

**ម.អ.ជ.** ត្រូវគ្រប់គ្រងដឹកនាំដោយក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃ **ម.អ.ជ.** ត្រូវកំណត់ដោយលក្ខន្តិកៈ ដែលនឹងត្រូវរៀបចំនិងសំរេចដោយក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។

សមាសភាពក្រុមប្រឹក្សាភិបាល **ម.អ.ជ.** មានជាអាទិ៍ ៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | ជាប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | ជាអនុប្រធាន |
| ៣. រដ្ឋលេខាធិការ នៃក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង | ជាអនុប្រធាន |
| ៤. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៥. តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦. ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ឬតំណាង | ជាសមាជិក |

៧. តំណាងក្រុមអ្នកផ្តល់ជំនួយដែលក្រុមនេះបានស្នើទៅរដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជាសមាជិក

៨. តំណាងផ្នែកហិរញ្ញវត្ថុដែលសមាគមធនាគារិកកម្ពុជា
បានស្នើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៩. តំណាងក្រុមហ៊ុនដែលបានចូលរួមក្នុងគំរោងអភិវឌ្ឍន៍អគ្គិសនីជនបទ
ដែលបានស្នើទៅ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

១០.តំណាងអង្គការក្រៅរដ្ឋាភិបាល ឬអង្គការអន្តរជាតិដែលបានចូលរួម
ក្នុងគំរោងអភិវឌ្ឍន៍ អគ្គិសនីជនបទ ដែលបានស្នើទៅរដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

១១.តំណាងមួយរូបរបស់អ្នកប្រើប្រាស់អគ្គិសនីជនបទ ជាសមាជិក

តំណាងនេះអាចជាសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់មួយរូប ក្នុងករណីដែលពុំទាន់មានតំណាងអ្នកប្រើប្រាស់អគ្គិសនីជនបទ ។

សមាជិកក្រុមប្រឹក្សាភិបាលមានអាណត្តិរយៈពេលពីរឆ្នាំ ហើយនៅពេលចប់អាណត្តិអាចបន្តបានតែម្តងទៀតសំរាប់រយៈពេលពីរឆ្នាំ។

**មាត្រា ៥.-**

ប្រភពផ្តល់មូលនិធិដល់ **ម.អ.ជ.** មានដូចខាងក្រោម ÷

១. អំណោយ និងជំនួយឥតសំណង ដែលប្រភពនិងល័ក្ខខ័ណ្ឌនៃការផ្តល់ ត្រូវបានទទួលការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២. ប្រភពដទៃទៀតពីរាជរដ្ឋាភិបាលដែលមានលក្ខណៈទៀងទាត់ និងសមល្មមក្នុងការអនុវត្តនូវគោលនយោបាយ និងគោលដៅអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ។

**មាត្រា ៦.-**

**ម.អ.ជ.** អនុវត្តភារកិច្ចរបស់ខ្លួន រហូតដល់ពេលដែលគោលនយោបាយអគ្គិសនីភាវូបនីយកម្មជនបទ សំរេចគោលដៅដែលបានកំណត់។

**មាត្រា ៧.-**

ដោយមិនឱ្យហួសពីរយៈពេលបីខែបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃព្រះរាជក្រឹត្យនេះ នាយករដ្ឋមន្ត្រី តែងតាំងប្រធាន អនុប្រធាន និងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។

រាជរដ្ឋាភិបាលត្រូវផ្តល់មូលនិធិដំបូងតាមរយៈក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលទៅឱ្យ **ម.អ.ជ.** សំរាប់កិច្ចប្រតិបត្តិការនៅពេលតែងតាំងក្រុមប្រឹក្សាភិបាល **ម.អ.ជ.** ។ **ម.អ.ជ.** ត្រូវតំកល់ប្រាក់នេះក្នុងគណនីដោយឡែកសំរាប់ប្រើការ ។ មានតែ **ម.អ.ជ.** ប៉ុណ្ណោះដែលមានសិទ្ធិប្រើប្រាស់ប្រាក់តំកល់នេះ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវផ្ទេរមុខងារ និងភារកិច្ចកំណត់ឱ្យដោយព្រះរាជក្រឹត្យនេះឱ្យទៅ **ម.អ.ជ.** ក្នុងពេលដែល **ម.អ.ជ.** ដំណើរការពេញលេញ ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច តាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១០.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣/ល.០៤១២.០៤៨

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា**
**នាយករដ្ឋមន្ត្រី**
ហត្ថលេខា
ហ៊ុន សែន

លេខ: ៣៧០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឈាងី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

## តែងតាំង

## លោក តាន់ សេងហាក់

## ជា

## ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៤១៧.០៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៤

លេខ: ៣០៧៦.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៥០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **គីង វណ្ណៈ** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកកសិកម្ម និងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៤*

*៣រស.០៤១២.០៥០*

លេខ: ...០៦២ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
សាយ៉ី ផាន

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្តតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **យូ គិមយាន** ទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៤១២.០៥៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០០៤*

លេខ: ៣០១៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១២០៤/០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឯកឧត្តម **ថោង ខុន** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៤១២.០៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

លេខ៖ ៣០៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារី តាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៨/០១១/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៦/០០៨/២០០៤ កបធ.ច
ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញលិខិតលេខ ៣០៣ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ពុំមានចំណុចណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

BIT

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៩០/០១៣/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៧/០០៩/២០០៤ កបធ.ច
ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩ កបធ.សសរ.ច ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលបានប្រកាសថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៩៩ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩ មិនស្របនឹងរដ្ឋធម្មនុញ្ញ

-បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ១២ កបធ.សសរ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ ដែលបានប្រកាសថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៩ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៩ ស្របនឹងរដ្ឋធម្មនុញ្ញ

-បានឃើញលិខិតលេខ ៣០៥ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតនេះនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលប្រធានរដ្ឋសភាសុំពិនិត្យធម្មនុញ្ញភាព ជាច្បាប់រៀបចំអង្គការមួយ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព ស្របតាមមាត្រា ១៤០ ថ្មី កថាខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ។

-យល់ឃើញថា មាត្រា ១ ដល់មាត្រា ៦ ដែលចែងពីការបង្កើតក្រសួងកិច្ចការនារី ស្របនឹងសេចក្តីសម្រេចនៃក្រុមប្រឹក្សាធម្មនុញ្ញលេខ ១២ កបធ.សសរ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ និងមិនមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៩/០១២/២០០៤
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**សេចក្តីសម្រេច**
លេខ : ០៦៨/០១០/២០០៤ កបធ.ច
ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញលិខិតលេខ ៣០៤ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីត-យុទ្ធជន និង យុវនីតិសម្បទា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ ( ឃ្លាទី ១ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ( ឃ្លាទី ២ មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ )

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

ក.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៨១...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល ផ្លាកសញ្ញាសម្រាប់ពាក់លើមួក ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍ និងឯកសណ្ឋានការងារលេខ៤ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ និងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣

* * * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និង ទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពីការកែសំរួលផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានលេខ៤ មួកបេរេ ការស្លៀកពាក់ឯកសណ្ឋានលេខ ៤ និងសញ្ញាអគ្គបញ្ជាការដ្ឋាន កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ

- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ នៅមាត្រា ៥ ត្រង់ចំណុច ក អំពីរូបព្រះសង្ហារ មាត្រា ៦ ត្រង់ចំណុចទី ១ ចំណុចទី ២ អំពីសញ្ញាថ្នាក់

ឧត្តមសេនីយ៍ និងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ ស្ដីពីការកែសម្រួលផ្លាកសញ្ញារូបបាឡុមាន សញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានការងារលេខ ៤ និងសញ្ញាអត្តបញ្ញាការកងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ នៅមាត្រា១ ត្រង់ចំណុចទី៣ អំពីឯកសណ្ឋានការងារ ត្រូវបានកែសម្រួលដូចខាងក្រោម ៖

**១-ផ្លាកសញ្ញាសំរាប់ពាក់លើមួក**

-រូបព្រះសង្ហារយកតាមសញ្ញាជាតិ ធ្វើពីលោហធាតុពណ៌មាសនៅលើវិណ្ឌព្រះសង្ហារ មានសរសេរអក្សរ **ព្រះចៅក្រុងកម្ពុជា** សំរាប់ពាក់លើមួកកាសស្កេត និងមួកស៊ីកាស ទំហំ កំពស់ ៧,៨ ស.ម ទទឹង ៦,៥ ស.ម សំរាប់ពាក់លើមួកហោហេ ទំហំ កំពស់ ៥ ស.ម និងទទឹង ៤ ស.ម

-រូបព្រះសង្ហារយកតាមសញ្ញាជាតិ ធ្វើពីអំបោះពណ៌មាស ប៉ាក់ភ្ជាប់នឹងមួកហ៊្វ័រកឹ មួកវាមចំផ្នែកខាងមុខ និងមួកបេរេ នៅខាងមុខផ្នែកខាងស្ដាំ ទំហំ កំពស់ ៥ ស.ម និង ទទឹង ៤ ស.ម ។

**២-ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍**

-ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍ គ្រប់លំដាប់ថ្នាក់មានតែមួយប្រភេទ ។

-រូបសញ្ញា ៖ ផលិតអំពីលោហធាតុពណ៌មាសមានរាងដូចស្នែងក្របី ផ្នែកខាងលើមានម្កុដ តំណាងឱ្យប្រជាជាតិខ្មែរ ផ្នែកខាងក្រោមមានលំពែងស្វាយសត្វ និងយុថ្កាតំណាងឱ្យកងទ័ពទាំងបីប្រភេទ ។ សញ្ញាផលិតអំពីក្រណាត់ពណ៌ខ្មៅ មានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាស សំរាប់ពាក់លើឯកសណ្ឋានប្រយុទ្ធ ។

-ខ្នាត ៖ -កំពស់រូបភាព ៤ ស.ម ទទឹង ៣ ស.ម

-កំពស់ម្កុដ ១,៨ ស.ម បាតក្រោមម្កុដ ១,៣ ស.ម

-កំពស់យុថ្កា ១,៦ ស.ម ចុងផ្លែយុថ្កា ពីម្ខាងទៅម្ខាង ២ ស.ម

កំពស់លំពែងដោយគិតពីដងយុថ្កា ០,៦ ស.ម

-ស្លាបសត្វរាងដូចស្នែងក្របី ម្ខាងមានស្លាប ៣ ជាន់ ( ជាន់ទី ១ = ១១ ស្លាប ទី២ = ៩ ស្លាប ទី៣ = ៧ ស្លាប ) កំពស់ ២៤ ម.ម ពីចុងម្ខាងទៅម្ខាង ៣៥ ម.ម ។

**៣- ឯកសណ្ឋានការងារលេខ ៤**

ក-ឯកសណ្ឋានការងារដៃខ្លី ៖

-ឯកសណ្ឋានការងារដៃខ្លី អាវពណ៌គ្រែអ៊ីកាត់ស្រុងដាក់ក្នុងខោ ហើយខោពណ៌គ្រែអ៊ី

-អាវដៃខ្លី ពណ៌គ្រែអ៊ីកខុប ប៉ូលស្មាសងខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរបិះចំកណ្ដាល ដេររត់ផ្ចិតមានគម្របរាងស្លឹកពោធិ ឡេវចម្លាពណ៌គ្រែអ៊ី

- ខោជើងវែង ពណ៌គ្រែអ៊ីមានក្លីពីរ

- មួកហោហេ ឬមួកបេរេពណ៌គ្រែអ៊ី

-ខ្សែក្រវ៉ាត់តូចពណ៌គ្រែអ៊ី ដូចខ្សែក្រវ៉ាត់ឯកសណ្ឋានលេខ ១

ខ-ឯកសណ្ឋានការងារដៃវែង ៖

-ឯកសណ្ឋានការងារដៃវែង មានរូបភាព និងម៉ូតដូចឯកសណ្ឋានការងារដៃខ្លីខាងលើ តែមានដៃវែង នៅចុងដៃអាវមានផែក និងដាក់ឡេវ

-ខោ មួកដូចឯកសណ្ឋានការងារដៃខ្លី

-ចំពោះនារី អាវដូចបុរស ខោជើងវែងកាត់ដូចបុរស ឡេវចំហៀង ឬសំពត់ហ៊្សិបមានផែកផងពីខាងក្រោយ ពណ៌គ្រែអ៊ីក្រោមជង្គង់ ។

★ ឯកសណ្ឋានការងារលេខ ៤ នេះសំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយ និងទំនាក់ទំនងការងារធម្មតា ។

**ការស្លៀកពាក់** ៖ពាក់អាវដៃខ្លី ឬដៃវែងពណ៌ត្រែអ៊ី នៅដៃអាវខាងស្តាំ ដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និងនៅដៃអាវខាងឆ្វេងពាក់សញ្ញាផ្លាកកងឯកភាព ។ ខោជើងវែងពណ៌ត្រែអ៊ី ខ្សែក្រវាត់តូចពណ៌ត្រែអ៊ី មួកបេរ៉េពណ៌ត្រែអ៊ី មានរូបព្រះសង្ហារនៅខាងមុខផ្នែកខាងស្តាំ និងមានសញ្ញាសក្តិនៅខាងមុខផ្នែកខាងឆ្វេង ឬមួកបេរេពណ៌ត្រែអ៊ី ស្បែកជើងស្បែកកខ្លីពណ៌ខ្មៅ និងស្រោមជើងខ្មៅ ។ ពាក់សញ្ញាប្រភេទទ័ព នៅកអាវផ្លាកឈ្មោះនៅខាងលើហោប៉ៅអាវស្តាំ បានុមានពាក់នៅនឹងឡេវហោប៉ៅអាវស្តាំសក្តិនៅលើស្មា ដែលមានហ្វុងសក្តិខ្មៅក្បាលស្រួច និងពាក់មេដាយ អាវជានិច្ចកាលត្រូវដាក់ក្នុងខោ ។ ចំពោះកងនាវាចរ និងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារតាមការកំណត់ខាងលើ ហើយពាក់គ្រឿងរូមផ្សំផ្សេងៗទៀត និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរ និងបណ្តាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅអាវស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

ចំពោះរូបភាពនៃឯកសណ្ឋានការងារដៃខ្លី និងដៃវែងមានគំរូក្នុងឧបសម្ព័ន្ធថ្មី នៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

ត្រង់ចំណុច ក មាត្រា៥ និងត្រង់ចំណុចទី ១ ទី ២ មាត្រា ៦ នៃអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ និងត្រង់ចំណុច ៣ មាត្រា ១ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់ ញឹក ប៊ុនឆៃ**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធថ្មី

នៃអនុក្រឹត្យលេខ៣៦.អនក្រ.បក.ចុះថ្ងៃទី.៣០.ខែ.វិច្ឆិកា.ឆ្នាំ២០០៤

**១/ខោអាវការងារ** ( ខោជើងវែងមានជីបភ្លីពីរទាំងសង្ខាង ) **និង មួកបេរ៉េ**



២/មួកហ៊្សកគី + ព្រះសង្ការ



**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧២ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា
## ជូនទីស្តីការគណៈរដ្ឋមន្ត្រី

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១០០៤/ ០០៥ .ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក , ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

មាត្រា២: យោងតាមការអនុវត្តតាមមាត្រា៤០ថ្មីនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស. ៩៤ .ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.៣០០ លានរៀល ( បួនពាន់បីរយលានរៀលគត់ ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូចៗ ) របស់ក្រសួង ស្ថាប័នដូចមានខាងក្រោម :

| | | |
|---|---|---|
| ១. ក្រសួងព្រះបរមរាជវាំង | ចំនួន | ១០៧ លានរៀល |
| ២. អគ្គលេខាធិការដ្ឋានរដ្ឋសភា | ចំនួន | ៣០០ លានរៀល |
| ៣. អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | ចំនួន | ១១ លានរៀល |
| ៤. ក្រសួងការពារជាតិ | ចំនួន | ៧០០ លានរៀល |
| ៥. ក្រសួងមហាផ្ទៃ ( ផ្នែកសន្តិសុខសាធារណៈ ) | ចំនួន | ៧៨ លានរៀល |
| ៦. ក្រសួងមហាផ្ទៃ ( ផ្នែករដ្ឋបាលទូទៅ ) | ចំនួន | ៣០០ លានរៀល |
| ៧. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច | ចំនួន | ៤៥ លានរៀល |
| ៨. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ចំនួន | ១៥០ លានរៀល |
| ៩. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ចំនួន | ៣០ លានរៀល |
| ១០. ក្រសួងពត៌មាន | ចំនួន | ៦០ លានរៀល |
| ១១. ក្រសួងសុខាភិបាល | ចំនួន | ៥០០ លានរៀល |
| ១២. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ចំនួន | ៧០ លានរៀល |
| ១៣. ក្រសួងពាណិជ្ជកម្ម | ចំនួន | ២០ លានរៀល |
| ១៤. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ចំនួន | ១០ លានរៀល |
| ១៥. ក្រសួងបរិស្ថាន | ចំនួន | ៥០ លានរៀល |
| ១៦. ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា | ចំនួន | ៤០ លានរៀល |
| ១៧. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ចំនួន | ១.០០០ លានរៀល |
| ១៨. ក្រសួងធម្មការ និង សាសនា | ចំនួន | ៣០ លានរៀល |
| ១៩. ក្រសួងកិច្ចការនារី | ចំនួន | ៣០ លានរៀល |
| ២០. ក្រសួងសាធារណការ និង ដឹកជញ្ជូន | ចំនួន | ៤០ លានរៀល |
| ២១. ក្រសួងទេសចរណ៍ | ចំនួន | ១៦៩ លានរៀល |
| ២២. ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | ចំនួន | ១៥០ លានរៀល |
| ២៣. ក្រសួងធនធានទឹក និង ឧតុនិយម | ចំនួន | ៣៥០ លានរៀល |
| ២៤. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ចំនួន | ៣០ លានរៀល |
| ២៥. អាជ្ញាធរសវនកម្មជាតិ | ចំនួន | ៣០ លានរៀល |

មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូចៗ ) ជូនទីស្តីការគណៈរដ្ឋមន្ត្រី ( គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ) សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយថ្មីក្នុងជំពូកទាំងនេះ តាមប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញប្រេងឥន្ធនៈ បូមទឹក គ្រោះរាំងស្ងួត ឆ្នាំ ២០០៤ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម, រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អគ្គលេខាធិការដ្ឋានរដ្ឋសភា, រដ្ឋមន្ត្រីក្រសួងការពារជាតិ, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច, រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, រដ្ឋមន្ត្រីក្រសួងព័ត៌មាន, រដ្ឋមន្ត្រីក្រសួងសុខាភិបាល, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល, រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, រដ្ឋមន្ត្រីក្រសួងបរិស្ថាន, រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា, រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា, រដ្ឋមន្ត្រីក្រសួងកិច្ចការនារី, រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន, រដ្ឋមន្ត្រីក្រសួងទេសចរណ៍, រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់, ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤១៧...អនក្រ-តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនឯកឧត្តម ឧត្តមសេនីយ៍ត្រី *Tang Hue* មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពការពារព្រំដែន ប្រជាជនវៀតណាម ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ ធ្វើអោយសន្តិសុខ និង ស្ថេរភាព រវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម មានលក្ខណៈល្អប្រសើរ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ×/

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច /
-ឯកសារ-កាលប្បវត្តិ

B.67

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៤១៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា ១** : តែងតាំងលោក **ឡុង រិទ្ធីរក្ស** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងបរិស្ថាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ខែ ៨ ធ្នូ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១២៤ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបានបរិច្ចាគធនធាន ជួយឧបត្ថម្ភដល់ការកសាងកងពលតូចលេខ ៧០ ដូចមានរាយនាមខាងក្រោម ÷

១-លោក **វ៉ន្ធ សុវណ្ណារ៉ា** ប្រធានក្រុមចល័តបង្ក្រាបបទល្មើសព្រៃឈើ
ថវិកាចំនួន ១០.៧០០ ដុល្លារ

២-លោកវរសេនីយ៍ត្រី **លី អុក** នាយរងការិយាល័យទី ២ កងពលតូចលេខ ៧០
ថវិកាចំនួន ១១.៧០០ ដុល្លារ

៣-លោកវរសេនីយ៍ត្រី **អ៊ុំ សុខជា** នាយរងការិយាល័យទី ៤ កងពលតូចលេខ ៧០
ថវិកាចំនួន ១២.១០០ ដុល្លារ

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៦៦៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

^^^^^

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

### ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូននាយទាហាន និង មន្ត្រីរាជការ ចំនួន ១៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម ÷

១-ឧត្តមសេនីយ៍ត្រី **ឌឹម សុខ** នាយករងទីចាត់ការ បុគ្គលិក អគ្គបញ្ជាការ

២-ឧត្តមសេនីយ៍ត្រី **មិម យឿន** នាយកសាលានាយទាហានចំរុះ

៣-វរសេនីយ៍ឯក **គួច ថាវី** នាយការិយាល័យអត្តសញ្ញាណប័ណ្ណ ទីចាត់ការបុគ្គលិកអគ្គបញ្ជាការ

៤-វរសេនីយ៍ទោ **សុខ សុវណ្ណនិត្យ** នាយរងការិយាល័យទី ២ កងពលតូចលេខ ៧០

៥-វរសេនីយ៍ទោ **មាស ស៊ីណា** នាយរងការិយាល័យទី ២ កងពលតូចលេខ ៧០

៦-វរសេនីយ៍ទោ **សេខ ឃួត** នាយរងការិយាល័យទី ៤ កងពលតូចលេខ ៧០

៧-វរសេនីយ៍ទោ **ឌុន ធិន** នាយរង ហិរញ្ញវត្ថុ កងពលតូចលេខ ៧០

៨-វរសេនីយ៍ត្រី **ឌុន ឡេង** នាយរងការិយាល័យទី ២ កងពលតូចលេខ ៧០

៩-វរសេនីយ៍ត្រី **ញឹក សេខ** មេបញ្ជាការរង វរៈអន្តរាគមន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១០-អនុសេនីយ៍ឯក **ឆា គា** មេបញ្ជាការ កងរាជអាវុធហត្ថ ខណ្ឌទួលគោក

១១-អនុសេនីយ៍ឯក **លី សុខហេង** ជំនួយការ ការិយាល័យទី ២ កងពលតូចលេខ ៧០

១២-លោក **ឡើម ខែម** មន្ត្រីគយ ស្នាក់ការត្រពាំងថ្លុង

១៣-លោក **គួច ចំរើន** អភិបាល ខេត្តមានជ័យ

១៤-លោក **ឃួងស្រេង** អភិបាលរង ខេត្តទួលគោក

១៥-លោក **ខៀវ សារ៉ន** ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូន រាជធានីភ្នំពេញ

**មាត្រា២** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល:**
ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីចំនួន ០២ រូប ដែលបានខិតខំអស់ពីកំលាំងកាយ-ចិត្ត ក្នុងការសាងសង់អាគារក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិថ្មី បានចប់សព្វគ្រប់ជាស្ថាពរ ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **តៀវ សុគំណ្ឌ** ស្ថាបត្យករ

២-លោក **ជា ប៊ូរ៉ា** ប្រធានក្រុមហ៊ុន អេ-អេ-អ៊ី-ឌី

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តនីការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

### សម្រេច

**មាត្រា ១:** តែងតាំងមន្ត្រីរាជការនៃក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោម :

១- លោក **ឈិន ឈាង** ជាទីប្រឹក្សាក្រសួងពត៌មាន មានឋានៈស្មើ អគ្គនាយករង

២- លោក **ច័យ ទុន្សី** ជាអគ្គនាយករង អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មាន

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ [illegible] អនក្រ.តត

## អនុក្រឹត្យ

### ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **ឈិន សារី** អត្តលេខ ០៧២៣៥ បច្ចុប្បន្នអនុប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ជាទីប្រឹក្សាសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារគ្រឿងញៀន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦១៩...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម /០៧០៤ /០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **មិត្តឱ្យ** ជូនអង្គភាពកងទ័ពប្រជាជនវៀតណាមចំនួន០២ ដែលមានស្នាដៃល្អ ក្នុងការធ្វើសហប្រតិបត្តិការជួយហ្វឹកហ្វឺន និង ជួយឧបត្ថម្ភ ដល់កងពលតូចលេខ៧០ នៃកងយោធពលខេមរភូមិន្ទ ក្នុងរយៈពេលកន្លងមក ដូចមានរាយនាមខាងក្រោម ÷

១- **យោធភូមិភាគទី៧ នៃកងទ័ពប្រជាជនវៀតណាម** ( **QUÂN KHU 7 QUÂN DÔI NHÂN DÂN VIÊT NAM** )

២- **ក្រុមសុខាភិបាល ០២ ក្រសួងការពារជាតិ នៃកងទ័ពប្រជាជនវៀតណាម**
**DOÂNY TÊ 02-BÔ QUÔC PHÔNG QUÂN DÔI NHÂN DÂNVIÊT NAM**

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ :៧០៥ សរណន.កសក

# សារាចរណែនាំ

## ស្តីពី

## វិធានការ អនុវត្តការងារបង្កបង្កើនផលស្រូវប្រាំង ឆ្នាំ ២០០៤-២០០៥

នៅរដូវវស្សាឆ្នាំ ២០០៤ នេះជាទូទៅចាប់តាំងពីដើមរដូវមក អាកាសធាតុមានលក្ខណៈអំណោយផលជាបង្គួរសមស្របដល់ការងារបង្កបង្កើនផល ទោះបីជាមានភាពរាំងស្ងួតនៅតំបន់ខ្លះក្នុងខេត្តមួយចំនួនដូចជាខេត្តតាកែវ កំពត ព្រៃវែង ស្វាយរៀង និងខេត្តកំពង់ចាមក៏ដោយ ។ ដោយឡែកតែខេត្តកំពង់ស្ពឺ មួយប៉ុណ្ណោះដែលភាពរាំងស្ងួតបានអូសបន្លាយចាប់តាំងពីដើមរដូវ រហូតដល់ពេលបច្ចុប្បន្ន ។

ដោយមានការយកចិត្តទុកដាក់អន្តរាគមន៍ តាមគ្រប់មធ្យោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាដើម្បីជួយដល់កសិករនោះ ផ្ទៃដីនៃការងារបង្កបង្កើនផលស្រូវ រដូវវស្សាឆ្នាំនេះសំរេចបានស្មើនឹងក៏រិតរដូវវស្សាឆ្នាំ ២០០៣កន្លងទៅ ។ ដំណាំស្រូវបានលូតលាស់ បែកគុម្ព គួរជាទី ពេញចិត្ត ។

ប៉ុន្តែចាប់តាំងពីពាក់កណ្តាលខែតុលាមក នៅទូទាំងប្រទេស ភ្លៀងបានផ្អាក និងឈានទៅរកការបញ្ចប់ទាំងស្រុង ធ្វើអោយដំណាំស្រូវដែលកំពុងលូតលាស់ល្អ ហើយភាគច្រើនបានឈានចូលដំណាក់កាលផើម និងកំណកួ ហើយនោះ ត្រូវទទួលរងការប៉ះពាល់ធ្ងន់ធ្ងរ និងឈានដល់ការខូចខាតស្ទើរតែទាំងស្រុង ។ ប្រឈមមុខនឹងសភាពការនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងប្រើប្រាស់អស់លទ្ធភាពនូវមធ្យោបាយដែលមាន ដើម្បីសង្គ្រោះការខូចខាត ។ ការបូមបាចបាន និងកំពុងបន្តដំណើរការពីប្រភពទឹកទាំងឡាយដែលមានរួមទាំង ស្ទឹង អូរ បឹងបួរទាំងឡាយដែលភាគច្រើនក៏ជាប្រភពទឹកសំរាប់ស្រូវរដូវប្រាំងខាងមុខផងដែរ ។

ទន្ទឹមនឹងនេះ ឆ្នាំនេះទឹកទន្លេមេគង្គបានស្រកចុះយ៉ាងលឿនរួមទាំងទឹក ស្ទឹង បឹងបួរនានាផង ហើយគួបផ្សំនឹងការបូមបាច សង្គ្រោះស្រូវវស្សានាពេលនេះ ធ្វើអោយបរិមាណទឹកថយចុះ និងបណ្តាលអោយមានការខ្វះខាតទឹកសំរាប់ស្រូវប្រាំង នាពេលខាងមុខ ។

ក្នុងគោលបំណងដើម្បីធានាអោយសំរេចបាន តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងធានាសុវត្ថិភាពស្បៀង ជាពិសេសកាត់បន្ថយការប្រឈមមុខនឹងការខ្វះខាតទឹកនៅរដូវប្រាំងខាងមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់អង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត-ក្រុងទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួន ដូចខាងក្រោម:

- ពិនិត្យលទ្ធភាពជាក់ស្តែងប្រភពទឹកសំរាប់រដូវប្រាំង ដើម្បីកំណត់អោយបានច្បាស់នូវទីតាំង និងផ្ទៃដីដែលអាចធានាការស្រោចស្រពបាន ហើយណែនាំដល់កសិករមុនចាប់ពីពេលដកស្ទូងរហូតដល់ប្រមូលផល
- បំផុសប្រជាកសិករ អោយបង្វែរផ្ទៃដីស្រូវប្រាំង ដែលមិនអាចធានាទឹកស្រោចស្រពបាន ទៅដាំដំណាំស្បៀង រួមផ្សំដទៃទៀតដែលត្រូវការទឹកតិចជាងដំណាំស្រូវ ដូចជា សណ្តែក ដំឡូងជ្វា ដំឡូងមី ត្រាវ ។ល។
- អប់រំបណ្តុះបណ្តាល បច្ចេកទេសដាំដុះដល់ប្រជាកសិករដើម្បីធានាការបង្កើនទិន្នផលអោយបានខ្ពស់ជាអតិបរិមា
- បំផុសប្រជាកសិករអោយរកមុខរបរផ្សេងៗបន្ថែមទៀត តាមស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាន នីមួយៗតាមគោលការណ៍ "ភូមិមួយផលិតផលមួយ "។

ជារួមអង្គភាពថ្នាក់កណ្តាល និងមូលដ្ឋានខេត្ត-ក្រុង គ្រប់ជាន់ថ្នាក់ត្រូវម្ចាស់ការបន្ថយកចិត្តទុកដាក់តាមដានសភាពការ និងជំរុញការងារផលិតកម្មជាប្រចាំ ព្រមទាំងរួមសហការដោះស្រាយការលំបាកផ្សេងៗជាមួយកសិករក៏ដូចជាមួយផ្នែកពាក់ព័ន្ធ ហើយរាយការណ៍អោយបានទាន់ពេលវេលា។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុងត្រូវមានវិធានការអនុវត្តអោយបានសមស្របដើម្បីធានាប្រសិទ្ធភាពក្នុងការសំរេចបាននូវបរិមាណផលិតផលកសិកម្មខ្ពស់នៅរដូវប្រាំង ២០០៤-២០០៥ សំដៅ ធានាសុវត្ថិភាពស្បៀង រួមចំណែកពង្រឹងដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ពន្លឿនកំណើនសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ខែ ធ្នូ ឆ្នាំ២០០៤

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍវិស័យកសិកម្ម និងជនបទ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "
- អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ៤២៥ ក.ក.ប.វ

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤

## ប្រកាស

## ស្តីពី

## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០៤ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករប្រចាំឆ្នាំ២០០៥

## សំរេច

ប្រការ១:. ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅឆ្នាំ ២០០៥ សំរាប់កម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារត្រូវបានកំណត់ដូចតទៅ:-

- បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែមករា
- បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា
- បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ២៣ ខែ កុម្ភៈ
- បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា
- បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៤ ១៥ និងថ្ងៃទី ១៦ ខែ មេសា

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី០២ ខែ ឧសភា ជំនួសថ្ងៃទី ០១ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

- បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ២៣ ខែ ឧសភា ជំនួសថ្ងៃទី ២២ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

- ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ២៦ ខែ ឧសភា

- បុណ្យទិវាកុមារអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ មិថុនា

- ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្ដេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុចំនួនមួយថ្ងៃគឺ ថ្ងៃទី ១៨ ខែ មិថុនា

- បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ចំនួនមួយថ្ងៃ គឺថ្ងៃទី ២៤ ខែ កញ្ញា

- បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ០៣ ០៤ និងថ្ងៃទី ០៥ ខែ តុលា ជំនួសថ្ងៃទី ០២ ខែ តុលា ដែលចំថ្ងៃអាទិត្យ

- បុណ្យទិវាសន្និសញ្ញាសន្តិភាពក្រុងប៉ារីសចំនួនមួយថ្ងៃ គឺថ្ងៃទី ២៤ ខែ តុលា ជំនួសថ្ងៃទី ២៣ ខែ តុលា ដែលចំថ្ងៃអាទិត្យ

- ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុចំនួនបីថ្ងៃ គឺ ថ្ងៃទី ៣១ ខែ តុលា ថ្ងៃទី ០១ និងថ្ងៃទី ០២ ខែវិច្ឆិកា ជំនួសថ្ងៃទី ៣០ ខែ តុលា ដែលចំថ្ងៃអាទិត្យ

- បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា

- ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុកចំនួនបីថ្ងៃ គឺ ថ្ងៃទី ១៥ ១៦ និង ថ្ងៃទី ១៧ ខែវិច្ឆិកា

- បុណ្យទិវាសិទ្ធិមនុស្សចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២**.- ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា ១៤៧ នៃ ច្បាប់ស្ដីពីការងារ ត្រូវអោយឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករនិយោជិតទាំងអស់។

**ប្រការ៣**.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ចម្លងជូន**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
"ដើម្បីជូនជ្រាប"
-ក្រសួងសង្គមកិច្ច ការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
-ខេត្ត ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-ដូចប្រការ៣
-រាជកិច្ច
"ដើម្បីផ្សាយ"
-ឯកសារ-កាលប្បវត្តិ

ញ៉ែប-ប៊ុនជិន